FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ

ឆ្នាំទី ២ លេខ ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៣

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

A Publication of the Cambodian Agricultural Research and Development Institute



# ការរៀបចំសហគមន៍ដើម្បីគ្រប់គ្រង កណ្ដុរស្រែ

កណ្ដុរស្រែ ជាកត្តាចង្រៃមួយក្នុងចំណោមកត្តាចង្រៃដែលធ្វើអោយបាត់បង់ទិន្នផលស្រូវយ៉ាងធ្ងន់ធ្ងរ។ ម្យ៉ាងទៀត សត្វកណ្ដុរមានការលំបាកក្នុងការកំចាត់បើសិនជាកសិករមិនបានសហការណ៏គ្នាល្អទេក្នុងការកំចាត់កណ្ដុរនេះ។ ដូចនេះ រាល់វិធានការណ៏កំចាត់ទាំងឡាយពុំសូវមានប្រសិទ្ធិភាពហើយចំណាយថវិកាច្រើនទៀតផង។ គំរោងនេះបានបង្កើតការគ្រប់គ្រងសត្វកណ្ដុរនេះជាលក្ខណៈជាការសហការគ្នា ឬជាសហគមន៏ ដោយប្រើប្រាស់វិធីសាស្ត្រ Trap-Barrier System (TBS: ធី-ប៊ី-អេស)។ ធី-ប៊ី-អេស មាននយ័ថាជាប្រពន្ធ័គ្រប់គ្រងសត្វកណ្ដុរស្រែមួយរួមមាន របាំងផ្លាស្ទិច អង្គប់ និងដំណាំធ្នាក់។ ប្រពន្ធ័គ្រប់គ្រងនេះទាមទារចាំបាច់នូវការចូលរួមរបស់កសិករទាំងអស់ដែលមានស្រែនៅក្បែរៗគ្នា។

## សារៈប្រយោជន៏នៃការរៀបចំសហគមន៍កសិករ



- ធ្វើអោយមានប្រសិទ្ធិភាពខ្ពស់ និងនិរន្តរភាពក្នុងការគ្រប់គ្រង
- ជំរុញការចូលរួមរបស់កសិករក្នុងការអនុវត្តការងារ
- បង្កើនសាមគ្គីភាពនៅក្នុងមូលដ្ឋាន
- បង្កភាពងាយស្រួលដល់ការអនុវត្តការងារ
- ជំរុញការចូលរួមវិភាគទានរបស់កសិករនៅក្នុងការអនុវត្តការងារ ដើម្បីកាត់បន្ថយការចំណាយថវិកា និង កំលាំងពលកម្មគ្រួសារ
- បង្កើនភាពទទួលខុសត្រូវរបស់កសិករ

អស្រ័យហេតុនេះការចងក្រងជាសហគមន៏ជាយុទ្ធវិធីដ៏សំខាន់ក្នុងការគ្រប់គ្រងកណ្ដុរស្រែដោយ ធី-ប៊ី-អេស។

## ជំហាននៃការរៀបចំក្រុមកសិករ



- ផ្សព្វផ្សាយពីវិធីសាស្ត្រ ធី-ប៊ី-អេស ដល់កសិករនៅទីកន្លែងដែលនឹងអនុវត្ត
- កំណត់ទីតាំងស្រែទទួលរងការបំផ្លាញពីសត្វកណ្ដុរលើស្រែកសិករ
- ជ្រើសរើសសមាជិកក្រុមកសិករចូលរួមក្នុងការអនុវត្ត
- ការឯកភាពនៅក្នុងក្រុមកសិករ និង
- ធ្វើទិវាស្រែបង្ហាញដល់កសិករក្នុងក្រុម។

## ការផ្សព្វផ្សាយវិធីសាស្ត្រ ធី-ប៊ី-អេស

អាជ្ញាធរមូលដ្ឋាន និងអ្នកបច្ចេកទេស ព្រមទាំងអ្នកផ្សព្វផ្សាយសហការជាមួយកសិករសកម្ម រៀបចំធ្វើការប្រជុំក្រុមកសិករតាមភូមិ ឬតំបន់ដែលមានការបំផ្លាញពីសត្វកណ្ដុរ។ ការប្រជុំនេះត្រូវផ្ដោតទៅលើចំណុចសំខាន់មួយចំនួនដូចខាងក្រោម :

- ផ្សព្វផ្សាយពីបច្ចេកទេស ធី-ប៊ី-អេស ដល់កសិករ
- បង្ហាញពីសារៈប្រយោជន៏នៃការប្រើប្រាស់ ធី-ប៊ី-អេស ក្នុងការគ្រប់គ្រងសត្វកណ្ដុរ
- ពន្យល់ពីសារៈប្រយោជន៏នៃការធ្វើការរួមគ្នាក្នុងសហគមន៏
- រៀបចំផែនការដើម្បីកំណត់តំបន់ទទួលរងការបំផ្លាញពីសត្វកណ្ដុរ។

## ការកំណត់តំបន់ទទួលរងការបំផ្លាញពីសត្វកណ្ដុរ

អ្នកសំរបសំរួល និងក្រុមកសិករ (ដែលយល់ដឹងពីទីតាំងភូមិសាស្ត្រច្បាស់លាស់) ត្រូវសិក្សាទីតាំងដែលមានការបំផ្លាញពីសំណាក់សត្វកណ្ដុរ។

- កំណត់ចំនួនតំបន់ដែលគ្រោងនឹងអនុវត្ត ធី-ប៊ី-អេស
- សិក្សាពីសក្ដានុពលនៃតំបន់ដើម្បីរៀបចំជ្រើសរើសកូនស្រែធី-ប៊ី-អេស
- កំណត់កូនស្រែ ធី-ប៊ី-អេស នៅក្នុងតំបន់ដែលបានជ្រើសរើស។

## ការជ្រើសរើសសមាជិកក្រុមកសិករចូលរួម

អាជ្ញាធរមូលដ្ឋានត្រូវធ្វើការជ្រើសរើសកសិករ ដើម្បីបង្កើតនូវក្រុមការងារសំរាប់អនុវត្ត ធី-ប៊ី-អេស។ ការជ្រើសរើសកសិករអោយចូលរួមត្រូវផ្អែកលើលក្ខណៈមួយចំនួនដូចខាងក្រោម :

- កសិករដែលមានកូនស្រែនៅជុំវិញកូនស្រែ ធី-ប៊ី-អេស (២០០ ម៉ែត្រជុំវិញ)
- ការចូលរួមរបស់កសិករត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត
- កសិករដែលទទួលរងនូវការបំផ្លាញពីសត្វកណ្ដុរ
- កសិករដែលមានចំណាប់អារម្មណ៍ និងយកចិត្តទុកដាក់លើការងារនេះ
- កូនស្រែ ធី-ប៊ី-អេស មួយត្រូវទទួលខុសត្រូវដោយក្រុមកសិករមួយក្រុម

## ការឯកភាពក្នុងក្រុមកសិករ

ការឯកភាពក្នុងក្រុម ជាការធ្វើការព្រមព្រៀងរវាងកសិករនៅក្នុងក្រុម ធី-ប៊ី-អេស។ ការព្រមព្រៀងនេះធ្វើឡើងដោយឡែកៗពីគ្នានៅក្នុងក្រុម ធី-ប៊ី-អេស នីមួយៗដោយមានការចូលរួមពីអ្នកសំរបសំរួល និងអាជ្ញាធរមូលដ្ឋាន។ ចំនុចសំខាន់ៗ ដែលលើកឡើងនៅក្នុងការងារនេះរួមមានៈ

- ជ្រើសរើសប្រធានក្រុមការងារនៅក្នុងក្រុម ធី-ប៊ី-អេស ដោយសមាជិកនៅក្នុងក្រុម ធី-ប៊ី-អេស របស់ខ្លួន
- កំណត់កំរិតការចូលរួមវិភាគទានពីសមាជិកក្នុងក្រុម ធី-ប៊ី-អេស
- កំនត់ទីតាំងកូនស្រែ ធី-ប៊ី-អេស និងម្ចាស់កូនស្រែ
- រៀបចំផែនការសកម្មភាពការងារក្នុងក្រុមដើម្បីដំណើរការ ធី-ប៊ី-អេស។

## ការរៀបចំស្រែបង្ហាញ

ដើម្បីអោយកសិករកាន់តែយល់ច្បាស់ពីបច្ចេកទេសនៃការរៀបចំ ធី-ប៊ី-អេស អ្នកសំរបសំរួល និងអាជ្ញាធរមូលដ្ឋានត្រូវរៀបចំធ្វើទិវាស្រែបង្ហាញដល់ក្រុមកសិករ ។ ទិវាស្រែបង្ហាញនេះរួមមានៈ

- កូនស្រែ ធី-ប៊ី-អេស គំរូត្រូវរៀបចំទុកជាមុន
- បង្ហាញពីបច្ចេកទេសនៃការរៀបចំសម្ភារៈ ការតំឡើងឧបករណ៍ក្នុង កូនស្រែ និង វិធីតាមដានកូនស្រែ ធី-ប៊ី-អេស
- បង្ហាញពីការលំបាក និង ភាពងាយស្រួលក្នុងការអនុវត្ត នូវបច្ចេកទេស ធី-ប៊ី-អេស ។





សំរាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យសេដ្ឋកិច្ចសង្គម មជ្ឈមណ្ឌលបណ្ដុះបណ្ដាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៏កសិកម្មកម្ពុជា នៅតាមបណ្ដោយផ្លូវជាតិលេខ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ០១ ភ្នំពេញ.

ទូរសព្ទ័លេខៈ( ៨៥៥-២៣ ) ៦៣១៩ ៦៩៣-៤ ទូរអក្ខរៈ cardi@cardi.org.kh វែបសាយៈ www.cardi.org.kh

SChea@cardi.org.kh TRIN@cardi.org.kh HUNYADANA@cardi.org.kh